ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា ក្រសួងបានបន្តសម្របសម្រួលវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ស្របតាមតួនាទីដែលមានចែងក្នុងច្បាប់ជាធរមាន ក៏ដូចជាស្របតាមស្មារតីចង់បានរបស់តំណាងភាគីកម្មករនិយោជិតដែលចង់ជួបចរចាជាមួយក្រុមហ៊ុនផ្ទាល់។ នៅរសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ នេះ ក្រសួងបានបន្តអញ្ជើញគូភាគីវិវាទមកជួបប្រជុំដោះស្រាយជាលើកទី៦ ក្រោមអធិបតីភាពរបស់ឯកឧត្តម ទេស រុក្ខាផល អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ក.ប. ដោយមានតំណាងភាគីកម្មករនិយោជិត រួមមាន លោកស្រី ឈឹម សុខន, លោកស្រី វី សុវណ្ណឌី, លោកស្រី សុន ស្រីពេជ្រ, លោកស្រី ហៃ សុភាព (លោកស្រី ឈឹម ស៊ីថរ បន្តអវត្តមាន ដោយសារមានធុរៈចាំបាច់) និងតំណាងនិយោជក រួមមានលោក **Hein Dames**, លោក ហាយ វលោត, លោកស្រី ឌី សីហា និងលោកស្រី រស់ ប៊ុនឡេង ដោយភាគីទាំងពីរបានលើកឡើងនូវមតិយោបល់ ដូចខាងក្រោម៖

**មតិរបស់សហជីព និងតំណាងកម្មករនិយោជិត៖**

១. សង្ឃឹមថានឹងមានពន្លឺខ្លះក្នុងការទទួលបានការដោះស្រាយ និងបានពិភាក្សាគ្នាអំពីជម្រើសដែលអាចទទួលបានលទ្ធផលឈ្នះ-ឈ្នះ សម្រាប់ភាគីវិវាទទាំងសងខាង។ ក្រុមហ៊ុនធ្លាប់បានប្រើពាក្យ "បេះដូងមនុស្សធម៌" ចំពោះប្រជាជនខ្មែរ ហេតុអ្វីត្រឹមបុគ្គលិក ២០០នាក់ ដែលគាត់ចង់បន្តការងារនៅក្នុងក្រុមហ៊ុន បែរជាមិនអាចទទួលយកពួកគាត់បាន ពួកយើងក៏ជាជនជាតិខ្មែរដែរ។ ដូចនេះ តំណាងកម្មករនិយោជិតនៅតែបន្តទាមទារឱ្យពិភាក្សាអំពីការទទួលយកកម្មករនិយោជិតចូលធ្វើការវិញ និងសង្ឃឹមថាភាគីកម្មករនិយោជិតនឹងទទួលបាននូវព័ត៌មានថ្មីពីក្រុមហ៊ុនលើសំណើទាមទារ ដែលជាសំណើដដែលនេះ។

២. ស្នើសុំទៅភាគីក្រុមហ៊ុនទទួលយកកម្មករនិយោជិតដែលបានបញ្ឈប់នេះ ចូលជាសមាជិកគ្រួសារក្រុមហ៊ុន ណាហ្គាវើលដ៍ (Naga Family) ឡើងវិញ ពីព្រោះកម្មករនិយោជិតកំពុងតែមានវិបត្តិ និងជម្រើសទទួលយកនេះធ្វើឱ្យក្រុមហ៊ុនក្លាយជាក្រុមហ៊ុនគំរូ។

៣. មិនយល់ឃើញថា គួរពិភាក្សាអំពីចំណុចវិវាទផ្សេងៗ តាមការលើកឡើងរបស់ក្រុមហ៊ុននោះទេ ពីព្រោះចំណុចវិវាទទី១ ដែលពាក់ព័ន្ធនឹងការទាមទារចូលធ្វើការវិញនេះ គឺជាជម្រើសរបស់បុគ្គលិក ដើម្បីលើកយកមកពិភាក្សា។ ដូចនេះ កម្មករនិយោជិតនៅតែចង់ឱ្យពិភាក្សាលើចំណុចវិវាទទី១ ជាមុន។ តំណាងកម្មករនិយោជិតមានចម្ងល់អំពីមូលហេតុអ្វីដែលក្រុមហ៊ុនតែងតែលើកឡើងឱ្យពិភាក្សាលើចំណុចវិវាទចំនួន៣ ផ្សេងទៀត។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

មតិរបស់តំណាងក្រុមហ៊ុន ណាហ្គាវើលដ៍៖

១. ថ្លែងអំណរគុណដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានបន្តខិតខំរៀបចំឱ្យមានកិច្ចប្រជុំនេះ។

២. បន្តបញ្ជាក់ជំហរថា ក្រុមហ៊ុនមិនអាចទទួលយកកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងាររួមឱ្យចូលធ្វើការវិញបានទេ ហើយក៏មិនពិចារណាក្នុងការដោះដូរតាមសំណើរបស់តំណាងកម្មករនិយោជិតនោះដែរ ដូចក្រុមហ៊ុនបានបញ្ជាក់នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២១ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ រួចមកហើយ។

៣. មិនអាចទទួលយកកម្មករនិយោជិតដែលនៅសល់ចំនួន ២០០នាក់ ដែលបានបញ្ឈប់ស្របតាមនីតិវិធីច្បាប់ ដែលមានចែងនៅក្នុងនីតិវិធីនៃការបញ្ឈប់ពីការងាររួម។ ការបញ្ឈប់នេះ ក្រុមហ៊ុនបានកំណត់លក្ខណៈវិនិច្ឆ័យដើម្បីកំណត់ថា បុគ្គលិកណាដែលត្រូវរងផលប៉ះពាល់ក្នុងការបញ្ឈប់ការងាររួមនេះ។

៤. នៅតែមានជំហរដោះស្រាយឱ្យបានលឿនជាមួយនឹងសហជីព។ ប៉ុន្តែ ក្រុមហ៊ុនស្នើឱ្យតំណាងកម្មករនិយោជិតលើកឡើងនូវជម្រើសផ្សេងទៀត ដែលជាជម្រើសដែលអាចទៅរួច ប្រសើរជាងជម្រើសបច្ចុប្បន្ននេះ ដើម្បីយកមកពិភាក្សា ហើយក្រុមហ៊ុននឹងរង់ចាំទទួលព័ត៌មានថ្មីពីខាងតំណាងកម្មករនិយោជិត។

៥. នៅតែបន្តស្នើសុំឱ្យតំណាងកម្មករនិយោជិតពិភាក្សាលើចំណុចវិវាទចំនួន៣ ផ្សេងទៀត ដែលអាចផ្តល់ប្រយោជន៍សម្រាប់កម្មករនិយោជិតភាគច្រើន។ ក្រុមហ៊ុនគិតថា គួរតែពិភាក្សាលើបញ្ហាដែលនៅសេសសល់ទាំងនោះព្រោះថា ទោះបីជាដោះស្រាយនៅទីណា ឬទៅស្ថាប័នតុលាការក៏ដោយ បញ្ហាទាំងអស់នៅក្នុងវិវាទក៏មុខតែនឹងលើកឡើងមកពិភាក្សាដដែល។ ក្រុមហ៊ុនយល់ឃើញថា ស្ថាប័នពាក់ព័ន្ធបានចំណាយពេលវេលាច្រើនក្នុងការជួយដោះស្រាយករណីនេះ ដូច្នេះភាគីវិវាទគួរតែប្រើប្រាស់ពេលវេលានេះឱ្យមានតម្លៃ។

ក្រោយពីការពិភាក្សាគ្នាយ៉ាងផុសផុល ភាគីទាំងពីរបានឯកភាព ដូចខាងក្រោម៖

១. ភាគីទាំងពីរ នៅមិនទាន់ឈានដល់ចំណុចព្រមព្រៀងគ្នានៅឡើយទេ។

២. កំណត់កាលបរិច្ឆេទប្រជុំបន្ទាប់ នៅថ្ងៃពុធ ទី៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទី ដើម្បីឱ្យភាគីទាំងពីរមានឱកាសពិចារណាឡើងវិញ អំពីលទ្ធភាពនៃការធ្វើសម្បទានគ្នាទៅវិញទៅមកដែលអាចឈានទៅបញ្ចប់វិវាទនេះ។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងសូមបញ្ជាក់ផងដែរថា បើទោះបីជាមិនទាន់មានការឯកភាពគ្នា ក៏ក្រសួងនឹងបន្តខិតខំធ្វើការសម្របសម្រួល និងកំណត់កាលបរិច្ឆេទប្រជុំបន្តបន្ទាប់ទៀត ស្របតាមតួនាទីដែលកំណត់ដោយច្បាប់ ក៏ដូចជាការទាមទាររបស់គូភាគី។

ជាថ្មីម្តងទៀត ក្រសួងស្នើឱ្យភាគីទាំងពីរមានការយោគយល់គ្នាខ្ពស់ក្នុងការចូលរួមដោះស្រាយបញ្ចប់វិវាទការងារនេះ, បន្តសហការជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធដោយសន្តិវិធី, និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។ យោងតាមនីតិវិធីច្បាប់ ប្រសិនបើវិវាទការងារនេះមិនអាចស្វែងរកដំណោះស្រាយបានដោយការផ្សះផ្សា នីតិវិធីបន្ទាប់គឺអាចបញ្ជូនទៅតុលាការ ដើម្បីរកដំណោះស្រាយចុងក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២